FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ៨ លេខ ៨៥ ខែមិថុនា ឆ្នាំ ២០០៩

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

A Publication of the Cambodian Agricultural Research and Development Institute



# ពូជសណ្តែកបាយ "ស៊ីអឹមប៊ី៣"

ពូជសណ្តែកបាយ ស៊ីអឹមប៊ី៣ "CMB3" ត្រូវបានបញ្ចេញដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ នាដើមឆ្នាំ ២០០៩ បន្ទាប់ពីបានធ្វើការពិសោធន៍អស់រយៈពេលប្រាំមួយរដូវ (បីឆ្នាំ) កន្លងមក។ ពូជនេះមានប្រភពដើមចេញពីស្រឡាយ ATF 3944 នាំចូលពីប្រទេសអូស្ត្រាលី។

## លក្ខណៈពិសេសៗរបស់ពូជសណ្តែកបាយ "ស៊ីអឹមប៊ី ៣"

**សណ្តែកបាយ** "ស៊ីអឹមប៊ី៣" ចេញផ្ការយៈពេល ៣០ ថ្ងៃ និងទុំប្រមូលផលលើកទីមួយរយៈពេល ៥០ ថ្ងៃ បន្ទាប់ពីដាំ។ ដើមដងមានពណ៌បៃតង រាងជ្រុងឈរត្រង់ កម្ពស់ដើមប្រែប្រួលពី ៥០-១០០ ស.ម បែកមែកពី ២-៤ មែក។ នៅលើដើម និងមែកមានរោមតូចៗឆ្មារ ។ ប្រព័ន្ធឫស មានឫសកែវ និងឫសរយាងដែលអាចចាក់ចូលទៅក្នុងដីជម្រៅ ពី ៥០-៦០ ស.ម ប៉ុន្តែ ៨០ ភាគរយ នៃប្រព័ន្ធឫសស្ថិតនៅជម្រៅពី ៥-២០ ស.ម។ នៅលើឫសមានកំពកឫសតូចៗ បង្កើតឡើងដោយវត្តមាននៃបាក់តេរីមួយចំនួនក្នុងពួករីហ្សូប្យូម ដែលមានសមត្ថភាពស្រូប និងភ្ជាប់អាសូត (N) សេរីពីបរិយាកាស និងក្នុងដី ។ ទម្រង់ស្លឹកមានលក្ខណៈពិសេសងាយរលួយនៅក្នុងដីដែលជាប្រភពជីធម្មជាតិដ៏ប្រសើរសម្រាប់ដំណាំផ្សេងៗទៀត ។ ផ្កាជាកញ្ចុំ ពេលរីកមានពណ៌លឿង ផ្លែមានរាងជាស៊ីឡាំងមូលទ្រវែង ផ្លែខ្ចីមានពណ៌បៃតងចាស់ និងផ្លែទុំមានពណ៌ខ្មៅ។គ្រាប់មានពណ៌បៃតង ចំនួនផ្លែក្នុង ១ ដើមពី ១២-២០ ផ្លែ។ ចំនួនគ្រាប់ក្នុងមួយផ្លែពី ៧-១៤ គ្រាប់ ទម្ងន់ ១០០០ គ្រាប់ស្មើ នឹង ៦០ ក្រាម និងទិន្នផលជាមធ្យម ៨៥៣ គីឡូក្រាមក្នុងមួយហិកតា និងមានសក្តានុពលទិន្នផល ១.៩០០ គីឡូក្រាមក្នុងមួយហិកតា។

## វិធីសាស្ត្រដាំដុះ

ពូជសណ្តែកបាយនេះ អាចដាំដុះបានពេញមួយឆ្នាំនៅតាមតំបន់ខ្ពង់រាបដោយបុកដាំជាជួរ ឬដាំតាមចង្អូរ និងដាំដោយព្រោះគ្រាប់ទៅលើដីដែលភ្ជួររួច ហើយរាស់លុប។ ចំពោះការដាំដោយបុករណ្តៅជាជួរគួរប្រើគម្លាត គុម្ព ២៥-៣០ គុណនឹង ៣៥-៤០ ស.ម និងជម្រៅពី ២-៣ ស.ម ដោយក្នុងមួយរណ្តៅដាក់គ្រាប់ចំនួន ២-៣ គ្រាប់។ រីឯការដាំតាមតំបន់ទំនាបគឺដាំបន្ទាប់ពីច្រូតស្រូវវស្សារួច ត្រូវលើករងចំងាយពី គ្នាប្រហែល៣០ស.មមួយ និងមានកំពស់១០ទៅ ១៥ ស.ម។ ការដាំដុះពូជសណ្តែកបាយ "ស៊ីអឹមប៊ី៣" លើផ្ទៃដីមួយហិកតា គឺបើដាំដោយបុកដាំជាជួរត្រូវការគ្រាប់ពូជពី ១៥-២០ គ.ក្រ/ហ.ត និងបើដាំដោយព្រោះ ត្រូវការគ្រាប់ពូជពី ៣០-៤០ គ.ក្រ/ហ.ត។








ក្រោយពីដាំបាន ១០-១៥ ថ្ងៃ គួរកាត់រំលោះកូនដោយទុកតែដើមណាដែលថ្លោស និងរឹងមាំល្អជាងគេចំនួន ១-២ ដើមក្នុងមួយគុម្ពនិងត្រូវដកស្មៅចង្រៃឲ្យបានស្អាត ចៀសវាងការដណ្តើមជីជាតិពីដំណាំដែលនាំឲ្យដំណាំដុះលូតលាស់យឺត។

## ការដុះលូតលាស់

ការធ្វើដីបានផុសល្អ ដីមានជីជាតិសំណើមគ្រប់គ្រាន់ និងធាតុអាកាសអំណោយផលក្រោយពីដាំបាន ៣ ថ្ងៃ គ្រាប់ចាប់ផ្តើមដុះទូលដីមកខាងលើ។ ចាប់ពីពេលដុះ ពន្លករហូតដល់អាយុ ១៥ ថ្ងៃ សណ្តែកមានការដុះលូតលាស់ពុំសូវលឿនប៉ុន្មានទេតែអាយុកាលចាប់ពី ២០ ថ្ងៃឡើងទៅសណ្តែកបាយមានការដុះលូតលាស់យ៉ាង លឿន។

| ឈ្មោះជី | កម្រិតជីទៅតាមក្រុមដី (គ.ក្រ / ហ.ត) | | |
|---|---|---|---|
| | ព្រៃខ្មែរ ប្រទះឡាង (ដីខ្សាច់-ល្បាយខ្សាច់) | កំពង់សៀម ឡាបានសៀក ទូលសំរោង (ដីល្បាយឥដ្ឋ) | គៀនស្វាយ (ដីល្បាយ) |
| ដេអាប៉េ | ១០០ | ១១០ | ៨៥ |
| ប៉ូតាស្យូម | ៥០ | ៥០ | ៥៥ |

## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីតាមបច្ចេកទេស និងត្រឹមត្រូវតាមពេលវេលា ធ្វើឲ្យដំណាំដុះលូតលាស់ល្អទទួលបានទិន្នផលខ្ពស់។ ជីដែលអាចប្រើប្រាស់គឺជីដេអាប៉េ និងប៉ូតាស្យូម។ ការប្រើប្រាស់ជី គឺជីដេអាប៉េ និងប៉ូតាស(១០០ភាគរយ) ដាក់ទ្រាប់បាតមុនពេលដាំ ១ ឬ ២។ ជីត្រូវដាក់ដោយកប់លប់ក្នុងដីជម្រៅ ៥-១០ ស.ម ការពារជីមិនឲ្យបាត់បង់តាមរយៈការហើរទៅក្នុងបរិយាកាស និងការហូរច្រោះដោយសារទឹកផង។ ចំពោះជីលាមកគោ ឬកំប៉ុស្តិ៍ កសិករអាចប្រើនៅពេលទ្រាប់បាតក្នុងកម្រិត ៥ ត/ហ.ត ឬ ០,៥ គ.ក្រ/ម$^{២}$ បន្ថែមលើជីគីមី បើសិនជាដីរបស់គាត់ខ្វះសារធាតុសរីរាង្គ។

## ការប្រមូលផល

ផ្លែសណ្តែកទុំអាចប្រមូលផលនៅរយៈពេល ២០ ថ្ងៃក្រោយចេញផ្កា (ចំនួនផ្លែលើសពី ៩០ ភាគរយ ចាប់ផ្តើមប្រែពណ៌ពីបៃតងក្រម៉ៅទៅជាខ្មៅ)។ គេអាចប្រមូលផលបាន ២-៣ លើក ក្នុងមួយវដ្តជីវិតរបស់វា។ គម្លាតពេលប្រមូលផលពីមួយលើកទៅមួយលើកមានរយៈពេល ៥-៧ថ្ងៃ។ ប៉ុន្តែការប្រមូលផលលើកទីបី ពុំសូវទទួលបានទិន្នផលច្រើនដូចលើកទីមួយ និងទីពីរទេ។ ការយឺតយ៉ាវក្នុងការប្រមូលផលជាហេតុ ធ្វើឲ្យទិន្នផលមានការបាត់បង់ដោយសារផ្លែទុំប្រេះនាំឲ្យជ្រុះគ្រាប់នៅរដូវប្រាំង ឬគ្រាប់សណ្តែកអាចដុះនៅក្នុងផ្លែបើមានភ្លៀងធ្លាក់ជាប់យូរថ្ងៃនៅរដូវវស្សា។

## ការទុកដាក់ក្រោយប្រមូលផល

ជាមធ្យមសំណើមគ្រាប់ក្រោយពេលប្រមូលផលពី ១៥-១៨ ភាគរយ ដូច្នេះតម្រូវឲ្យយើងធ្វើការហាលសម្ងួតបន្ថែមទៀតដោយកម្តៅថ្ងៃ។ ការយឺតយ៉ាវក្នុងការហាលសម្ងួតក្រោយពេលប្រមូលផល និងការទុកដាក់គ្រាប់មិនបានត្រឹមត្រូវ គឺងាយរងការបំផ្លាញពីពពួកសត្វល្អិតចង្រៃដូចជាខ្មូតជាដើមដោយវាស៊ីចោះ ផ្នែកខាងក្នុងរបស់គ្រាប់ដែលធ្វើឲ្យមានការ បាត់បង់ទាំងទិន្នផលគុណភាព និងតម្លៃ។

## ការរក្សាទុកគ្រាប់ពូជ

ពូជសណ្តែកបាយ "ស៊ីអឹមប៊ី៣" ជាពូជដែលមានស្ថេរភាពសេនេទិច និងអាចរក្សាទុកគ្រាប់ពូជដាំបានទៀតពី ២-៣ រដូវកាលប្រសិនបើ យើងធ្វើការបន្សុទ្ធពូជបានត្រឹមត្រូវ។ ការរក្សាទុកគ្រាប់ពូជ សម្រាប់ ប្រើប្រាស់នៅរដូវបន្ទាប់ គឺគ្រាប់ពូជត្រូវមានសំណើមពី ១២-១៣ ភាគរយ ហើយត្រូវរក្សាទុកនៅកន្លែងដែលគ្មានសត្វល្អិត គ្មានខ្យល់ចេញចូល ឬទុកនៅក្នុងធុងបិទជិត ឬអាចរក្សាទុកដោយប្រើប្រាស់ ថ្នាំការពារសត្វល្អិត។



សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh

ទូរអក្ខរ: ssophany@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh